ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃព្រហស្បតិ៍ ១១ កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ២០១៧ ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់បានដំណើរការសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០១៧ និងលើកទិសដៅការងារឆ្នាំ ២០១៨ ដែលមានសមាជិកចូលរួមសរុបប្រមាណចំនួន ៨០០ រូប។ អង្គសន្និបាតបានឯកភាពទាំងស្រុងលើរបាយការណ៍លទ្ធផលការងារឆ្នាំ ២០១៧ របស់ក្រសួង និងទិសដៅការងារឆ្នាំ ២០១៨ ដូចខាងក្រោម÷

1. គាំទ្រ និងអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីរួមចំណែកការពារសន្តិភាព ស្ថេរភាពនយោបាយ សេដ្ឋកិច្ច និងសង្គម ឯករាជ្យ អធិបតេយ្យភាព និងការរីកចម្រើនរបស់ប្រទេសជាតិ។
2. រៀបចំប្រព័ន្ធទិន្នន័យចុះបញ្ជីដីនិងប្រព័ន្ធផ្តល់ព័ត៌មានសង្ខេបតាមQR Code លើសន្លឹកប័ណ្ណកម្មសិទ្ធិដី។
3. រៀបចំប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងទិន្នន័យសំណង់ភ្ជាប់ទៅនឹងប្រព័ន្ធព័ត៌មានភូមិសាស្ត្ររបស់កម្មវិធី Google Map។
4. រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យផ្តល់សេវាសាធារណៈតាមប្រព័ន្ធព័ត៌មានវិទ្យានិងរៀបចំដំណើរការផ្តល់សេវាចុះបញ្ជីក្រុមហ៊ុន និងសហគ្រាសសាងសង់តាមប្រព័ន្ធអនឡាញ (Online)។
5. រៀបចំបទដ្ឋានក្នុងការប្តូរប្រភេទដី ដើម្បីពង្រឹងការគ្រប់គ្រង និងប្រើប្រាស់ដីឱ្យអស់សក្តានុពលនៃដីព្រមទាំងបង្កើតប្រភពចំណូលចូលថវិកាជាតិ។
6. ជំរុញការប្រកាសតំបន់វិនិច្ឆ័យតាមភូមិនៅទូទាំងប្រទេស ដើម្បីពន្លឿនការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ដែលបច្ចុប្បន្នសម្រេចបាន ៦៦,៤% នៃក្បាលដីប៉ាន់ស្មានសរុបចំនួនប្រមាណ ៧ លានក្បាលដី។
7. បន្តពង្រឹងកិច្ចសហការជាមួយរដ្ឋបាលរាជធានី ខេត្ត ពន្លឿនការដោះស្រាយវិវាទដីធ្លី ដើម្បីសុវត្ថិភាពនៃការកាន់កាប់ដី និងភាពសុខដុមរមនាក្នុងសង្គម។
8. បន្តជំរុញការអភិវឌ្ឍវិស័យសំណង់ដែលទុនវិនិយោគនៅឆ្នាំ ២០១៧ មានជាង ៦.៤០០ លានដុល្លារអាមេរិក កើនឡើងជិត ២២% ធៀបនឹងឆ្នាំ ២០១៦ និងផ្តល់ការងារធ្វើប្រចាំថ្ងៃជូនយុវជនប្រមាណ ២០ ម៉ឺននាក់ ។
9. ផ្សព្វផ្សាយនិងអនុវត្តនូវបទដ្ឋានចិញ្ចើមផ្លូវនិងផ្លូវថ្មើរជើងសាធារណៈសម្រាប់សាធារណជន និងជនពិការ។
10. គ្រប់គម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សំណង់ផ្តល់សេវាជូនសាធារណជន និងទីលានសាធារណៈ ដូចជា បណ្តាញផ្លូវ ផ្លូវថ្មើរជើង ចិញ្ចើមផ្លូវ សួនច្បារ ចំណតយានយន្ត ស្ថានីយរថភ្លើង ព្រលានយន្តហោះ អគាររដ្ឋបាល សាលារៀន គ្រឹះស្ថានអប់រំ មន្ទីរពេទ្យ មណ្ឌលសុខភាព និងគម្រោង

សាងសង់បុរី លំនៅឋាន សណ្ឋាគារ ភោជនីយដ្ឋាន ផ្សារ រោងចក្រ និងអគារឯកជនផ្សេងៗទៀត ត្រូវចាត់ចែងឱ្យមានទីកន្លែង បរិក្ខារ និងសេវាសម្រាប់ជនពិការគ្រប់ប្រភេទ ដូចជា ការរៀបចំផ្លូវជម្រាល ផ្លូវដើរ ជណ្តើរ បង្កាន់ដៃសុវត្ថិភាព ភ្លើងសញ្ញា ស្លាកសញ្ញានិងបរិក្ខារជំនួយសុវត្ថិភាពផ្សេងៗសម្រាប់ជនពិការ។

11. បន្តពង្រឹងការគ្រប់គ្រងការដ្ឋានសំណង់ និងដាក់ចេញនូវវិធានការទាន់ពេលវេលា ទប់ស្កាត់បទល្មើសសំណង់គ្រប់ប្រភេទ ព្រមទាំងលើកទឹកចិត្តនូវស្ថាបត្យកម្មដែលមានរចនាបថខ្មែរ។
12. បន្តការពារដីចំណីឆ្នេរនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ដោយរៀបចំយុទ្ធសាស្ត្រជាតិសមាហរណកម្មការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ផែនការរៀបចំដែនដីខេត្ត ប្លង់គោលប្រើប្រាស់ដីក្រុង ផែនទីឆ្នេរសមុទ្រ ដីចំណីឆ្នេរសមុទ្រ និងប្លង់គោលប្រើប្រាស់ដីកោះ នៅខេត្តទាំង ៤ នៃតំបន់ឆ្នេរសមុទ្រកម្ពុជា។
13. ជំរុញកសាងប្លង់បែងចែកតំបន់ប្រើប្រាស់ដី និងសន្ទស្សន៍ប្រើប្រាស់ដីនៅក្នុងខណ្ឌទាំង ៤ កណ្តាលរាជធានីភ្នំពេញ មានខណ្ឌដូនពេញ ខណ្ឌ៧មករា ខណ្ឌទួលគោក និងខណ្ឌចំការមន។
14. ជំរុញការអនុម័តផែនការរៀបចំដែនដីខេត្តព្រះសីហនុ ផែនការរៀបចំដែនដីខេត្តបាត់ដំបង ប្លង់គោលក្រុងសៀមរាប ប្លង់គោលក្រុងកំពត ប្លង់គោលក្រុងកែប ប្លង់គោលក្រុងខេមរភូមិន្ទ ប្លង់គោលក្រុងកំពង់ចាម ប្លង់គោលក្រុងតាខ្មៅ ផែនការប្រើប្រាស់ដីខណ្ឌនៃរាជធានីភ្នំពេញ និងប្លង់គោលទីប្រជុំជនជ្រៃធំ ខេត្តកណ្តាល។
15. បន្តផ្តល់ដីសម្បទានសង្គមកិច្ច និងសាងសង់ផ្ទះជូនគ្រួសារយោធិន និងនគរបាល គ្រួសារអតីតយុទ្ធជន ពលី ពិការ មរណៈនិងបាត់បង់សមត្ថភាពការងារដែលមានជីវភាពក្រីក្រ គ្មានដី គ្មានផ្ទះ កំពុងឈរជើងនៅតាមបណ្តោយព្រំដែន។
16. បន្តពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជនក្នុងការអនុវត្ត"**គោលនយោបាយលើកទឹកចិត្ត និងការបង្កើតកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ**" ជូនមន្ត្រីរាជការ និងប្រជាពលរដ្ឋដែលមានចំណូលមធ្យម ចំណូលទាប និងជនងាយរងគ្រោះ។
17. បន្តគាំទ្រនិងចូលរួមអនុវត្តកាន់តែសកម្មលើកម្មវិធីកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ពិសេសការកែទម្រង់លើវិស័យដីធ្លីនិងសំណង់ កំណែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។
18. បន្តធ្វើប្រតិភូកម្មដល់រដ្ឋបាលស្រុកដែលបានរៀបចំលក្ខណសម្បត្តិសមស្របចំនួន ៤៤ ស្រុក បន្ថែមទៀតក្នុងការចេញលិខិតអនុញ្ញាតសាងសង់លំនៅឋានដែលមានផ្ទៃក្រឡាសំណង់ មិនលើសពី ៥០០ ម២ និងកម្ពស់មិនលើសពី ២ ជាន់ គិតទាំងជាន់ផ្ទាល់ដី ដើម្បីឈានទៅសម្រេចបាន ៩០ ក្រុង ស្រុក ខណ្ឌ ត្រឹមឆ្នាំ ២០១៨ ដែលបច្ចុប្បន្ន បានធ្វើប្រតិភូកម្មជូនដល់ក្រុង ស្រុក ខណ្ឌ ចំនួន ៤៦ រួចហើយ។
19. បន្តពង្រឹងការប្រមូលចំណូលចូលថវិកាជាតិ ដែលនៅឆ្នាំ ២០១៧ នេះ ប្រមូលចំណូលបានជិត ៩៣ លានដុល្លារ កើនឡើង ២១ លាន ដុល្លារធៀបនឹងឆ្នាំ ២០១៦។

អាស្រ័យហេតុនេះ សូមសាធារណជនជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ២០១៧